ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣៤៧

ចុះថ្ងៃទី ២៥_០៥_២០០៥

សាលដីកា

លេខ : ១១០ "ខ"

ចុះថ្ងៃទី ០៥_០៩_២០០៧

## នាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

**********

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ០៥-០៩-២០០៧ ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្ដម [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខៈ ៣៤៧ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ ដែលមានៈ

**១- ជនជាប់ចោទឈ្មោះ** [redacted] **លីនដា** ភេទស្រី អាយុ ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិស្នេហ៍ ឃុំបាភ្នំ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃផ្ទះ [redacted] ៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ មុខរបរលក់បាយ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ប្ដីឈ្មោះ [redacted] មានកូន ៦នាក់ ទោសពីមុនគ្មាន។

**២- ជនជាប់ចោទឈ្មោះ** [redacted] **ឡោម** ភេទស្រី អាយុ ៥៤ឆ្នាំ ជាតិខ្មែរ កើតនៅភូមិសណ្ដាន់ ឃុំសណ្ដាន់ ស្រុកសំបូរ ខេត្តក្រចេះ ទីលំនៅសព្វថ្ងៃផ្ទះ [redacted] សង្កាត់វាលវង់ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) ប្ដីឈ្មោះ [redacted] មានកូន ៦នាក់ ទោសពីមុនគ្មាន។

**ត្រូវជាប់ចោទពីបទៈ** ជួញដូរមនុស្សឱ្យធ្វើពេស្យាចារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រត់មនុស្ស និងជួញដូរមនុស្ស។

- **ជនរងគ្រោះឈ្មោះ** [redacted] **ស្រីលីន** ភេទស្រី អាយុ ១៧ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៣ឃ ផ្លូវ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា ក្រុងភ្នំពេញ។

- **ជនរងគ្រោះឈ្មោះ** [redacted] **ស្រីលាភ** ភេទស្រី អាយុ ១១ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ ១៥ សង្កាត់ផ្សារថ្មី ខណ្ឌដូនពេញ ក្រុងភ្នំពេញ។

- តាមពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៤០ ឈ ចុះថ្ងៃទី ០៩-០៥-២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] លីនដា៖

បណ្តឹងឧទ្ធរណ៍លេខ ២៥ ឈ ចុះថ្ងៃទី ០៨-០៤-២០០៥ របស់ជនជាប់ចោទឈ្មោះ[redacted] **ឡោម** និងបណ្តឹងឧទ្ធរណ៍លេខ ៣៨ ឈ ចុះថ្ងៃទី ០៩-០៥-២០០៥ របស់ឈ្មោះ [redacted] **គីមលន់** ជាមេធាវីការពារជនរងគ្រោះ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤-០៣-២០០៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

**ដំណើររឿងមានដូចតទៅៈ**

កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ សមត្ថកិច្ចចម្រុះចុះបង្ក្រាបករណីជួញដូរមនុស្សឱ្យធ្វើពេស្យាចារនៅចំណុចខណ្ឌទួលគោក និងខណ្ឌដូនពេញ សមត្ថកិច្ចបានឃាត់ជនល្មើស ២នាក់ រួចបញ្ជូនមកតុលាការតែម្តង ឯក្មេងស្រីបានប្រគល់មកអង្គការ IJM គ្រប់គ្រងជាបណ្តោះអាសន្ន។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ដែលបានសម្រេចសេចក្តីដូចខាងក្រោមៈ**

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted] **លីនដា ហៅ ស្រីនាង** ភេទស្រី អាយុ ៤០ឆ្នាំ ទីលំនៅសព្វ[redacted] ១៥៤ សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ និងឈ្មោះ[redacted]ឡាម ភេទស្រី អាយុ ៥៤ឆ្នាំ ទីលំនៅសព្វថ្ងៃផ្ទះលេខ [redacted] ១២ សង្កាត់វាលវង់ ខណ្ឌ ៧មករា ក្រុងភ្នំពេញ ដាក់ពន្ធនាគារក្នុងម្នាក់ៗ ១១ឆ្នាំ (ដប់មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន ពីបទ ជួញដូរមនុស្សឱ្យធ្វើពេស្យាចារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ តាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់មនុស្ស និងជួញដូរមនុស្ស។

២- វត្ថុតាងដែលដកហូតបានពីជនល្មើសមានលុយដុល្លាចំនួន ២.០០០ដុល្លា (ពីរពាន់ដុល្លាអាមេរិក) ត្រូវប្រគល់ឱ្យអង្គការ IJM ចាប់ពីពេលនេះតទៅ។

៣- សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍រយៈពេល ២ខែ គិតចាប់ពីថ្ងៃនេះតទៅ។

- បានឃើញ ពាក្យបណ្តឹងឧទ្ធរណ៍លេខ ៤០ ឈ ចុះថ្ងៃទី ០៩-០៥-២០០៥ របស់ជនជាប់ចោទឈ្មោះ[redacted]**លីនដា**, បណ្តឹងឧទ្ធរណ៍លេខ ២៥ ឈ ចុះថ្ងៃទី ០៨-០៤-២០០៥ របស់ជនជាប់ចោទឈ្មោះ[redacted] **ឡោម** និងបណ្តឹងឧទ្ធរណ៍លេខ ៣៨ ឈ ចុះថ្ងៃទី ០៩-០៥-២០០៥ របស់ឈ្មោះ [redacted] **គីមលន់** ជាមេធាវីការពារជនរងគ្រោះ ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤-០៣-២០០៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

**នាពេលសវនាការ**

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនរងគ្រោះឈ្មោះ[redacted] ស្រីលាភ បានឆ្លើយនៅតុលាការក្រុងភ្នំពេញ។

ជនជាប់ចោទឈ្មោះ [redacted] **លីនដា** ឆ្លើយថាៈ ខ្លួនពិតជាបានយកកូនខ្លួនឈ្មោះ [redacted] **ស្រីលាភ** ទៅលក់ប្រាកដមែន។ ហើយខ្លួនទទួលបានប្រាក់ ២.០០០ដុល្លា។ ពេលប្រគល់ក្មេងទាំង ២នាក់ ខ្លួនទទួលបានតែ ១០០ដុល្លា ទេ ហើយគេសន្យាថា ឱ្យខ្លួន ២.០០០ដុល្លា ទៀត។ ពេលខ្លួនទទួល ១០០ដុល្លា ខ្លួនបានឱ្យទៅអ្នកបកប្រែ ៥០ដុល្លា ហើយឱ្យទៅ[redacted] ឡោម

១០ដុល្លា។ ហើយពេលខ្លួនយក [redacted] ស្រីលីន ទៅលក់ឱ្យជនបរទេសនោះឈ្មោះ [redacted] ឡោម យល់ព្រម។ សំណូមពរសុំតុលាការបន្ធូរបន្ថយទោសឱ្យខ្លួនផង។

ជនជាប់ចោទឈ្មោះ [redacted] ឡោម ឆ្លើយថា: ខ្លួនមិនបានយកកូនទៅលក់ទេ កូនខ្លួនបាត់ ហើយខ្លួនរកកូន ស្រាប់តែប៉ូលីសចាប់ខ្លួនតែម្តង។ ខ្លួនស្គាល់ឈ្មោះ [redacted] លីនដា តាមរយៈទៅផ្សារ ឯកូនខ្លួនក៏ស្គាល់ [redacted] លីនដា ដែរ។ ខ្លួនបានយល់ព្រមលក់កូនខ្លួនមែន។

ជនរងគ្រោះឈ្មោះ [redacted] ស្រីលីន ឆ្លើយថា: ម្តាយខ្លួនមិនបានយកខ្លួនទៅលក់ទេ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

សូមក្រុមប្រឹក្សាពិចារណាអំពីអំពើ និងការសារភាពរបស់ជនជាប់ចោទ ឯវត្ថុតាងនៃអំពើល្មើស គឺមិនត្រូវប្រគល់ទៅឱ្យអង្គការទេ គឺត្រូវតែប្រគល់ជូនរដ្ឋ។ ដូច្នេះ មហាអយ្យការសាលាឧទ្ធរណ៍សូមសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល។

- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីលីន
- ក្រោយពីបានស្តាប់អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីលាភ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍លេខ ៤០ ឈ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] លីនដា បណ្តឹងឧទ្ធរណ៍លេខ ២៥ ឈ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៥ របស់ជនជាប់ចោទឈ្មោះ [redacted] ឡោម និងបណ្តឹងឧទ្ធរណ៍លេខ ៣៨ ឈ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] គឹមលន់ ជាមេធាវីការពារជនរងគ្រោះ ធ្វើឡើងនៅក្នុងកំណត់ច្បាប់។

២- ជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅ ស្រីនាង ពិតជាបានយកកូនស្រីខ្លួនឈ្មោះ [redacted] ស្រីលាភ ជាអនីតិជនអាយុក្រោម ១៥ឆ្នាំ និងឈ្មោះ [redacted] ស្រីលីន ជាអនីតិជនអាយុក្រោម ១៨ឆ្នាំ ទៅលក់ឱ្យជនបរទេស កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ ដើម្បីឱ្យបម្រើផ្លូវភេទ ហើយបានទទួលប្រាក់ពីជនបរទេសនោះ ២.០០០ដុល្លាអាមេរិក ប្រាកដមែន។ ឯជនជាប់ចោទឈ្មោះ [redacted] ឡោម បាននាំកូនស្រីខ្លួនឈ្មោះ [redacted] ស្រីលីន ជាអនីតិជនអាយុក្រោម ១៨ឆ្នាំ ទៅលក់ឱ្យឈ្មោះ [redacted] លីនដា ដើម្បីឱ្យទៅបម្រើផ្លូវភេទជនបរទេស កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ នោះដែរ។

៣- តាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ស្រីលីន ថា នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ម្តាយខ្លួនឈ្មោះ [redacted] ឡោម បាននាំខ្លួនទៅផ្ទះ [redacted] លីនដា ហើយគាត់ជួបគ្នានិយាយគ្នា ពុំដឹងនិយាយពីអ្វីទេ តែឃើញឈ្មោះ [redacted] លីនដា ឱ្យលុយគាត់ លុះពេលត្រឡប់ទៅផ្ទះវិញ ម្តាយខ្លួនបានប្រាប់ខ្លួនថា កូនឯងកុំយំ កុំភ័យ កុំខ្លាចអី។ លុះស្អែកឡើង គឺថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ ឈ្មោះ [redacted] លីនដា បាននាំខ្លួន និង [redacted] ស្រីលាភ ទៅផ្ទះជនបរទេសនោះ ហើយជនបរទេសឱ្យលុយ [redacted] លីនដា ១៧ដុល្លាអាមេរិក។

៤- មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] លីនដា ហៅ ស្រីនាង និង [redacted] ឡោម ពីបទ ជួញដូរមនុស្សឱ្យធ្វើពេស្យាចារ ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០០៤ បទល្មើសមានចែង និងឱ្យផ្តន្ទាទោស តាមមាត្រា ៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់មនុស្ស និងជួញដូរមនុស្ស ។

៥- សាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ក- ទទួលបណ្តឹងឧទ្ធរណ៍លេខ ២៥ ឈ ចុះថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០០៥ របស់ជនជាប់ចោទ ឈ្មោះ [redacted] ឡោម និងបណ្តឹងឧទ្ធរណ៍លេខ ៤០ ឈ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៥ របស់ជនជាប់ចោទ ឈ្មោះ [redacted] លីនដា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផុយនឹងគតិច្បាប់ ។

ខ- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៨ ឈ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] គឹមលន់ ជាមេធាវីការពារជនរងគ្រោះ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផុយនឹង គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៥ "ឈ" ចុះថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៥ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ២០០៧ ចំពោះមុខជនជាប់ចោទ និងជនរងគ្រោះឈ្មោះ [redacted] ស្រីលីន កំបាំងមុខជនរងគ្រោះឈ្មោះ [redacted] ស្រីលាភ ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០០៧ កំបាំងមុខជនជាប់ចោទ និងជនរងគ្រោះ តែទុកជាចំពោះមុខ បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និង ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និង កងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ៣០ ខែ 12 ឆ្នាំ២០១០

ក្រឡាបញ្ជី

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]